# ប្រកាសលេខ

# ១៤៧

# ស្តីពីសៀវភៅ

# ការងារកម្មករ

# និយោជិត៍ខ្មែរ

www.ekasar.com

00065

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ ២៤៥ សកបយ

ភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## សៀវភៅការងារកម្មករនិយោជិតខ្មែរ

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស.រកម-០៣៩៧-០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

www.ekasar.com



# សំ ទេ ច

ប្រការ ១: ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារ មិនអាចប្រើកម្មករនិយោជិតខ្មែរដោយគ្មានសៀវភៅការងារឡើយ ហើយត្រូវបង្កលក្ខណៈងាយស្រួលឱ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទៅធ្វើសៀវភៅការងារ នៅឯនាយកដ្ឋានមុខរបរ និងពលកម្ម នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះអ្នកនៅរាជធានីភ្នំពេញ និងនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនីមួយៗ ចំពោះអ្នកនៅខេត្តក្រុង។

ប្រការ ២ : នៅពេលស្នើសុំសៀវភៅការងារកម្មករនិយោជិតម្នាក់ៗត្រូវយកទៅជាមួយនូវ :

- ពាក្យស្នើសុំសៀវភៅការងារមិនតែមប្រិយ៍ ១ ០០០ រៀល ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខ ទំហំ ៣ គុណ ៤សម ចំនួន ៥សន្លឹក ចំនួន ០១ ច្បាប់
- អត្តសញ្ញាណប័ណ្ណជនជាតិខ្មែរ ឬ លិខិតបញ្ជាក់សញ្ជាតិខ្មែរដែលចេញឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច ឬលិខិតផ្ទាល់ខ្លួនថាជាជនជាតិខ្មែរដោយមានការបញ្ជាក់របស់កម្មករដែលធ្វើការជាមួយគ្នាចំនួន២នាក់ដែលមានអត្តសញ្ញាណជាខ្មែរ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់មុខរបរដែលចេញឱ្យដោយម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន ចំនួន ០១ ច្បាប់
- អាករសៀវភៅការងារដែលកំណត់ឱ្យបង់តែម្តងគត់ចំនួន១ ៥០០រៀល( មួយពាន់ប្រាំរយរៀលគត់ ) ។

ប្រការ ៣ : ពេលជាមួយគ្នានឹងការចេញសៀវភៅការងារ នាយកដ្ឋានមុខរបរ និងពលកម្ម ឬ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនីមួយៗ ក៏មានចេញជូនសាមីជនកម្មករនិយោជិតផងដែរនូវ " ប័ណ្ណសំគាល់កម្មករនិយោជិតខ្មែរ " ។

ប្រការ ៤ : នៅពេលដែលមានកម្មករនិយោជិតចូលធ្វើការ ឬឈប់ពីការងារ សហគ្រាសគ្រឹះស្ថានណាមួយ ម្ចាស់ ឬ នាយកសហគ្រាសគ្រឹះស្ថាន ត្រូវយកសៀវភៅការងាររបស់កម្មករនិយោជិតនោះ ទៅចុះទិដ្ឋាការចូល ឬ ចេញ នៅឯនាយកដ្ឋានមុខរបរនិងពលកម្ម នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះអ្នកនៅរាជធានីភ្នំពេញ ឬនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនីមួយៗ ចំពោះអ្នកនៅខេត្តក្រុង។ ការចុះទិដ្ឋាការនេះត្រូវធ្វើក្នុងរយៈពេលមិនលើសពី ៧ថ្ងៃ គិតចាប់ពីថ្ងៃដែលសាមីកម្មករនិយោជិតបានចូលធ្វើការ ឬ ឈប់ពីការងារ ។

នៅពេលដែលមានការផ្លាស់ប្តូរមុខងារ និងប្រាក់ឈ្នួល របស់កម្មករនិយោជិតម្តងៗ ម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន ក៏ត្រូវយកសៀវភៅការងារទៅចុះទិដ្ឋាការឱ្យបានត្រឹមត្រូវដូចពេលចូលធ្វើការ ឬឈប់ពីការ

www.ekasar.com



ងារផងដែរ ។

នៅពេលដែលកម្មករនិយោជិតឈប់ពីការងារ ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាស ត្រូវប្រគល់សៀវភៅការងារជូនដល់សាមីជនកម្មករនិយោជិតវិញ ។

ប្រការ៥ : ម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន មិនត្រូវបានអនុញ្ញាតិឱ្យយកសៀវភៅការងារកម្មករនិយោជិតទៅប្រើប្រាស់ខុសពីគោលដៅឡើយ ហើយក៏មិនអាចចារមូលវិចារអ្វីទៅលើសៀវភៅការងារនោះផងដែរ ។

ប្រការ ៦: អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញតិទាំងឡាយនៃប្រកាសនេះ នឹងត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូក១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ ៧ : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
-សហភាពសហជីព

"ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុង
-សមាគមនិយោជក

"ដើម្បីអនុវត្ត"

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍

"ដើម្បីជួយផ្សព្វផ្សាយ"

-កាលប្បវត្តិ-ឯកសារ